ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៩៧ អនក្រ.

# សេចក្តីសម្រេច
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើដែលមានសមាសភាពដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្តមនាយឧត្តមសេនីយ៍ សៅ សុខា | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ប្រធាន |
| ២. ឯកឧត្តមឧត្តមសេនីយ៍ឯក ហ៊ី សាគុណ | អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន | អនុប្រធាន |
| ៣. ឯកឧត្តម ឆេង គឹមស៊ុន | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤. ឯកឧត្តម ផៃ ប៊ុនឈឿន | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៥. ឯកឧត្តម ប្រាជ្ញ ចន្ទ | អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ | សមាជិក |
| ៦. ឯកឧត្តម ស រ ចំរុង | អភិបាលនៃគណៈអភិបាលខេត្តក្រចេះ | សមាជិក |
| ៧. ឯកឧត្តម លន់ លឹមថៃ | អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម | សមាជិក |
| ៨. ឯកឧត្តម អេង ប៊ុនហ៊ាង | អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី | សមាជិក |
| ៩. ឯកឧត្តម ថង សាវុន | អភិបាលនៃគណៈអភិបាលខេត្តរតនគិរី | សមាជិក |
| ១០. ឯកឧត្តម ម៉ុម សារឿន | អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង | សមាជិក។ |

www.pheakdeylaw.com

ប្រការ ២.-

គណៈកម្មការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើមានតួនាទី និងភារកិច្ចដូចតទៅ៖

- ចុះទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ព្រៃឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសព្រៃឈើនានា នៅកាតព្វសាននៃប្រទេស
- ស្រាវជ្រាវរកអ្នកដែលពាក់ព័ន្ធនឹងសកម្មភាពកាប់ និងនាំចេញឈើល្មើសច្បាប់
- ចាប់ជនល្មើស និងវត្ថុតាងនៃបទល្មើសព្រៃឈើ ហើយរៀបចំកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី
- សហការជាមួយភាគីវៀតណាមនិងឡាវ ដើម្បីមានសហប្រតិបត្តិការល្អនិងប្រសិទ្ធភាព ក្នុងករណីចាំបាច់
- បូកសរុបរបាយការណ៍អំពីលទ្ធផលការងាររបស់គណៈកម្មការជាតិនេះជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ប្រការ ៣.-

សមាសភាពនៃគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំរបស់គណៈកម្មការនេះបាន។

ប្រការ ៤.-

គណៈកម្មការជាតិនេះ មានសិទ្ធិបង្កើតក្រុមប្រតិបត្តិការមួយតាមការចាំបាច់ ដែលមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម និងស្នើសុំកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទចូលរួមជាកម្លាំងក្នុងពេលចុះបេសកកម្ម។

ប្រការ ៥.-

គណៈកម្មការជាតិនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

គណៈកម្មការជាតិនេះអាចទទួលការឧបត្ថម្ភថវិកាសមស្របពីកញ្ចប់ថវិកាពិសេសរបស់រាជរដ្ឋាភិបាលសម្រាប់ដំណើរការការងាររបស់ខ្លួន។

គណៈកម្មការជាតិនេះមានសិទ្ធិប្រើប្រាស់ឧទ្ធម្ភាគចក្រពីរគ្រឿងរបស់កងទ័ពអាកាសនៃកងយោធពលខេមរភូមិន្ទ ដើម្បីបំពេញបេសកកម្មការងាររបស់ខ្លួន។

ប្រការ ៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com